## សមាគមភ្នំនាងកង្រី

## PHNOM NEANG KONGREY ASSOCIATION

# វគ្គបណ្តុះបណ្តាល

## ស្តីពី

## ការតស៊ូមតិ សិទ្ធិសេរីភាព និងភារកិច្ចស្របច្បាប់

## ក្នុងការគ្រប់គ្រងធនធានធម្មជាតិ/ធនធានជលផលរបស់សហគមន៍មូលដ្ឋាន

# TRAINING WORKSHOP
# ON
# ADVOCACY LEGAL RIGHTS AND RESPONSIBILITIES OF NATURAL RESOURCE/FISHERIES MANAGEMENT
# BY
# LOCAL COMMUNITIES

**Prepared & organized by Mr. Mom Samoeun, Project Staff**

# និយមន័យនៃការតស៊ូមតិ

កាលពីមុនពាក្យ អាត់វ៉ូខែត "Advocate" គឺសំដៅទៅលើអ្នកដែលការពារអ្នកដទៃ ជាពិសេសគឺមេធាវីដែលការពារកូនក្តីនៅមុខតុលាការ ។ ការតស៊ូមតិគឺមិនត្រូវបានគេប្រើប្រាស់ទូលំទូលាយក្នុងផ្លូវច្បាប់ឡើយ ។ បច្ចុប្បន្ននេះដូចដែលយើងបានដឹងអាត់វ៉ូខែតត្រូវបានគេហៅថា សកម្មជនដែលទទួលឬគាំទ្រយ៉ាងសកម្មនូវសកម្មភាពផ្សេងៗសំរាប់បុព្វហេតុនយោបាយ ។ ទោះជាយ៉ាងណាក៏ដោយ អត្ថន័យនៃការតស៊ូមតិកំពុងតែវិវឌ្ឍន៏ និងរួមបញ្ចូលនូវភាពជាសកម្មជនផងដែរ ។

ខាងក្រោមនេះគឺជានិយមន័យមួយចំនួននៃការតស៊ូមតិ :

ការតស៊ូមតិ គឺជាដំណើរការដែលធ្វើអោយមានឥទ្ធិពលទៅលើការសំរេចចិត្ត (Oxfam America)

☞ ការតស៊ូមតិ រួមមានសកម្មភាពនានាដែលបានគ្រោងទុក ដើម្បីទាក់ទាញអារម្មណ៏របស់សហគមន៍ទៅនឹងចំណោទបញ្ហា និងឈានឆ្ពោះទៅរកអ្នកធ្វើគោលនយោបាយ ដើម្បីស្វែងរកដំណោះស្រាយ ។ វារួមបញ្ចូលសកម្មភាពនយោបាយស្របច្បាប់ ដែលមានឥទ្ធិពលទៅលើបែបបទនៃច្បាប់ និងការអនុវត្តន៍ច្បាប់ ។ ការតស៊ូមតិគឺផ្តួចផ្តើមគំនិតដោយទាមទារអោយមាននូវអង្គការ យុទ្ធសាស្រ្តនៃការគិត ព៏តមាន ការទំនាក់ទំនង និងចលនា (ក្បួនសិទ្ធិមនុស្សដោយ Marge Schuler) ។

☞ ការតស៊ូមតិ គឺការដាក់បញ្ចូលបញ្ហានៅក្នុងរបៀបវារៈ ផ្តល់នូវដំណោះស្រាយ និងការឧបត្ថម្ភគាំទ្រដល់សកម្មភាពទាំងពីរខាងលើនេះ (ការណែនាំទៅរកការតស៊ូមតិ គំរូណែនាំនៃការបណ្តុះបណ្តាលដោយ Ritu R. Shama និងវិទ្យាបណ្ឌិតសភាសំរាប់ការអភិវឌ្ឍន៍ការអប់រំ 1997) ។

☞ ការតស៊ូមតិ គឺទាក់ទងទៅនឹងយុទ្ធសាស្រ្តផ្សេងៗគ្នា ក្នុងគោលបំណងបង្កើនឥទ្ធិពលសំរាប់ធ្វើការសំរេចចិត្តនៅកំរិត មូលដ្ឋាន ខេត្ត ជាតិ និងអន្តរជាតិ ។

## និយមន័យនៃការតស៊ូមតិជាភាសាខ្មែរ

នៅថ្ងៃទី ១៩ ឧសភា ១៩៩៨ សមាជិករបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាបានធ្វើការជួបប្រជុំគ្នា ដើម្បីពិភាក្សារកភាសាខ្មែរមានន័យប្រហាក់ប្រហែលយកមកបកប្រែពាក្យថា អែតវ៉ូកាស៊ី "Advocacy" ខាងក្រោមនេះជាសេចក្តីដកស្រង់ពីការប្រជុំ :

គ្មានពាក្យខ្មែរណាមួយដែលអាចពន្យល់អត្ថន័យពេញលេញនូវន័យនៃពាក្យអង់គ្លេស "Advocacy" បានទេ ។ គេតែងតែបកប្រែដោយងាយថា គាំទ្រ (Support) ការបកប្រែនេះធ្វើអោយមានការចាប់អារម្មណ៍ខុសបើប្រៀបធៀបនឹងគោលបំណងរបស់ NGO Forum ហើយនិងបង្កើតអោយមានការភ័ន្តច្រឡំ ។ ដូចនេះយើងគួរតែពិភាក្សាទាំងអស់គ្នាដើម្បីរកពាក្យសមស្របមួយ ។ មានការបកប្រែប្រាំយ៉ាងដែលពេលខ្លះត្រូវបានគេយកមកប្រើប្រាស់ :

1/ kaa chor-chaa nung tor waa → ការចរចានិងតវ៉ា
meaning ( Negotiation and protest)

2/ kaa koem tror mete → ការគាំទ្រមតិ
meaning ( Supporting an idea )

3/ kaa taq teanh mete → ការទាក់ទាញមតិ
meaning ( Drawing attention to an idea)

4/ kaa tor soo mete → ការតស៊ូមតិ
meaning ( Struggling for an idea)

5/ kaapie mete → ការពារមតិ
meaning (Defending an idea)

មាននិយមន័យផ្សេងៗនៃការតស៊ូមតិ ។ ការតស៊ូមតិរួមមាននូវយុទ្ធសាស្ត្រផ្សេងៗដែលមានឥទ្ធិពលទៅលើភូមិ មូលដ្ឋាន ខេត្ត ជាតិ និងអន្តរជាតិ ។ ការតស៊ូមតិគឺជាសកម្មភាពដែលត្រូវបានធ្វើដោយផ្តោតទៅលើគំនិតនៃបញ្ហាជាក់លាក់ ដើម្បីមានឥទ្ធិពលទៅលើអ្នកធ្វើការសំរេចចិត្ត ឬអ្នកធ្វើច្បាប់ ដើម្បីទទួលបានលទ្ធផល

សមស្របមួយ ។ ការតស៊ូមតិគឺជាការនិយាយ ចំពោះមុខសាធារណជនដើម្បីការពារអ្វីមួយ ឬទទួលបានអ្វីមួយ ឬគាំទ្រផលប្រយោជន៍ដោយចូលរួមនូវចលនាកុះករ ។

មានការពិភាក្សាមួយយ៉ាងវែងដូចតទៅ :

ទី ១ គឺជួយដល់សហគមន៍ដើម្បីពង្រីក/អភិវឌ្ឍន៍នូវគំនិតរបស់ពួកគេ និងប្រមូលផ្តុំគំនិតទាំងនោះ ។

ទី ២ យើងយកគំនិត គាំទ្រគំនិតតស៊ូ ការពារនូវគំនិតទាំងអស់ ។

ទោះជាយ៉ាងណាក៏ដោយ ពាក្យតស៊ូមតិ គឺដើម្បីលើកឡើងនូវការព្រួយបារម្ភ ។ ពាក្យ គាំទ្រមតិ ទាមទារមតិ តស៊ូមតិ ការពារមតិ ទាំងអស់នេះគឺសំដែងនូវអត្ថន័យនៃ ការតស៊ូមតិនៅក្នុងកិច្ចមួយ ។

ពាក្យនិមួយៗមានមូលដ្ឋានរបស់វា ។ ដូចជាពាក្យវៀតណាម យើងត្រូវប្រើប្រយោគយ៉ាងវែងជាភាសាខ្មែរ ដើម្បីពន្យល់នូវអត្ថន័យតែទោះបែបណាក៏ដោយក៏យើង អាចយល់ពីអត្ថន័យរបស់វាដែរ ។ នៅក្នុងសម័យអាណានិគមបារាំង យើងបានយកពាក្យ បារាំងជាច្រើនមកប្រើតែឥឡូវនេះយើងបានយកពាក្យអង់គ្លេស ជាច្រើនមកប្រើប្រាស់ប៉ុន្តែយើង គួរសំរេចចិត្តថាពាក្យខ្មែរណាមួយដែលត្រូវយកមកប្រើអោយសមស្រប ។ ទាំងអស់គ្នាបានសំរេចចិត្តថាយកពាក្យ ការតស៊ូមតិ ។ នៅពេលដែលយើងតស៊ូគំនិតជាធម្មជាតិ គឺគាំទ្រ ផ្តោតអារម្មណ៍ទៅលើគំនិតនោះ ហើយក៏ការពារគំនិតនោះផងដែរ ។ ដូចនេះពាក្យ តស៊ូមតិនេះគឺមានន័យទាំងអស់ ។

# ការតស៊ូមតិ ទល់នឹង ការបញ្ចុះបញ្ចូល

ការតស៊ូមតិ និងការបញ្ចុះបញ្ចូលពេលខ្លះក៏អាចប្រើជំនួសគ្នាបាន ។ ការបញ្ចុះបញ្ចូលទោះជាយ៉ាងណាក៏ដោយគឺជាទំរង់ជាក់លាក់មួយនៃការតស៊ូមតិ ។ ការបញ្ចុះបញ្ចូលគឺជាការជាក់ស្តែងក្នុងគោលបំណង ដើម្បីមានឥទ្ធិពលទៅលើច្បាប់ ។ ការតស៊ូមតិគឺជាពាក្យទូលំទូលាយដែលយោងទៅនឹងការអនុវត្តន៍សំរាប់ឱ្យមានឥទ្ធិលពលទៅលើការសំរេចចិត្ត ។ នៅសហរដ្ឋអាមេរិក ការបញ្ចុះបញ្ចូលគឺត្រូវបានគេសំដែងដោយភ្នាក់ងារដែលហៅថា **អ្នកបញ្ចុះបញ្ចូល** ។

អ្នកបញ្ចុះបញ្ចូលទាំងនោះ ជារបស់ក្រុមមួយដែលមានការចាប់អារម្មណ៍ជាក់លាក់ ដែលត្រូវបានគេដឹងថាជាការបញ្ចុះបញ្ចូល ។ អ្នកបញ្ចុះបញ្ចូលអាចស្នើសុំបោះឆ្នោតគាំទ្រ ឬប្រឆាំងការតាក់តែងច្បាប់ដែលមិនទាន់សំរេច ។

ពាក្យបញ្ចុះបញ្ចូល គឺត្រូវបានគេដកស្រង់មកពី វិធីសាស្រ្តដែលភ្នាក់ងារទាំងនេះបានប្រឈមមុខនឹងអ្នកតាក់តែងច្បាប់ក្នុងកន្លែងទទួលភ្ញៀវ ឬក្នុងបន្ទប់ទូលំទូលាយដោយផ្ទាល់នៅក្រោមអ្នកតាក់តែងច្បាប់នៅសភា ។ ពួកគេបានស្នាក់នៅក្នុងកន្លែងទទួលភ្ញៀវនៃអង្គនិតិបញ្ញត្តិដើម្បីជួបអ្នកធ្វើច្បាប់ទាំងនោះ ។

# ការអភិវឌ្ឍន៍សហគមន៍ និងការតស៊ូមតិ

ការតស៊ូមតិ គឺជាផ្នែកមួយនៃការងារអភិវឌ្ឍន៍សហគមន៍ ពីព្រោះជាការផ្តល់អំណាចឱ្យប្រជាជន និងការអភិវឌ្ឍន៍ធនធានមនុស្ស គឺជាគោលបំណងចុងក្រោយនៃការអភិវឌ្ឍន៍សហគមន៍ ។ ទោះជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍន៍សហគមន៍ ជាទូទៅបានអនុវត្តជាក់ស្តែងនៅកម្ពុជា គឺតែងតែមិនបញ្ចូលការតស៊ូមតិជាមួយទេ ។ ស្ថានភាពនេះគឺកំពុងតែផ្លាស់ប្តូរច្រើនឡើងៗ ដែលអង្គការក្នុងស្រុកទទួលស្គាល់នូវតួនាទីយ៉ាងសំខាន់របស់ពួកគេ ក្នុងការធ្វើការតស៊ូមតិ ។ តារាងប្រៀបធៀបខាងក្រោមបង្ហាញនូវភាពដូចគ្នា(ចំនុចលេខ ១) និងភាពខុសគ្នារវាងគំរោងអភិវឌ្ឍន៍សហគមន៍ធម្មតា និងការតស៊ូមតិ(ចំនុចលេខ ២ និងលេខ ៣) ។

| គំរោងអភិវឌ្ឍន៍សហគមន៍ធម្មតា | ការតស៊ូមតិ |
|---|---|
| 1. ធ្វើការដើម្បីអភិវឌ្ឍន៍ | 1. ធ្វើការដើម្បីអភិវឌ្ឍន៍ |
| 2. អ្នកទទួលផល  | 2. មុខសញ្ញាតស៊ូមតិ  |
| 3. លក្ខណៈនៃអ្នកទទួលផល ជាទូទៅតែងតែមានសិទ្ធិអំណាច ឥទ្ធិពល ឬមានធនធានតិចតួចជាងអ្នកអនុវត្តន៍ CD ។ អ្នកទទួផលតែងតែជាអ្នកសហគមន៍មូលដ្ឋាន ឬក្រុមដែលទន់ខ្សោយ ។ | 3. លក្ខណៈនៃមុខសញ្ញាតតស៊ូមត : តែងតែមានអំណាច សិទ្ធិ ឥទ្ធិពល ឬធនធានច្រើនជាអ្នកធ្វើការងារតស៊ូមតិ ។ គាត់អាចសំរេចចិត្តទៅលើចំណោទ /បញ្ហាតស៊ូមតិ ។ មុខសញ្ញាការតស៊ូមតិតែងតែមកពីរដ្ឋាភិបាល/ រដ្ឋ ពីព្រោះពួកគេសន្មត់ថាជា តួនាទីនៃសិទ្ធិ អំណាច និងអ្នកធ្វើគោលនយោបាយ ។ |

នៅក្នុងការអនុវត្តន៍គំរោងអភិវឌ្ឍនិសហគមន៏ គ្មានត្រូវការអំពាវនាវ ឬសុំទាមទារពីអ្នកណាម្នាក់ដែលតែងតែខ្ពស់ជាង និងក្នុងឋាន:ខ្ពស់ដើម្បីសំរេចចិត្តនៅលើមូលហេតុរបស់យើង ។

មុខសញ្ញាតស៊ូមតិគឺជាអ្នកកែក្នុងឋាន: ដើម្បីសំរេចចិត្តទៅលើបុព្វហេតុគោលដៅ ឬគោលបំណងដែលគាំទ្រការងារដែលគេកំពុងធ្វើ ។ ពួកគេតែងតែជាអ្នករាជការ/រដ្ឋ ។

ការចង្អុលបង្ហាញខាងក្រោមនេះ នឹងបញ្ជាក់ច្បាស់នូវការបែងចែកគ្នារវាង ការអភិវឌ្ឍន៍សហគមន៍ និងការតស៊ូមតិ ។




គ្រប់ៗគ្នាអាចជាអ្នកតស៊ូមតិ ដូចជាអ្នកធ្វើការ NGOs អ្នកភូមិ ឬក៏មកពីរដ្ឋបាល/រដ្ឋ ដរាបណាគាត់មានមូលហេតុច្បាស់លាស់ ។

NGOs អាចធ្វើការតស៊ូមតិទៅលើមូលហេតុនានាដែលគេមាន ។ ពួកគេក៏អាចធ្វើការតស៊ូមតិក្នុងនាមជាអ្នកមូលដ្ឋានឬជាដៃគូជាមួយអ្នកមូលដ្ឋាន ។



អ្នកមូលដ្ឋានអាចធ្វើការតស៊ូមតិក្នុងនាមខ្លួនគេផ្ទាល់ ។ ពួកគេអាចបង្ហាញនូវអំណាចខ្លាំង និងគួរឱ្យជឿ ប្រសិនបើពួកគេត្រូវបានរៀបចំ ។







ឧទាហរណ៍ :

ទោះបីជាចំណោទ ឬបញ្ហាដែលអាចដោះស្រាយបានដោយវិធីសាស្ត្រនៃការអភិវឌ្ឍន៍សហគមន៍ធម្មតា ឬការតស៊ូមតិ គឺវាអាស្រ័យដោយការផ្លាស់ប្តូរគោលបំណងរបស់យើង ។ ប្រសិនបើការផ្លាស់ប្តូរគោលបំណងនេះបានទទួលជោគជ័យដោយវិធីសាស្ត្ររបស់យើង ហើយដោយគ្មានតម្រូវការអំពាវនាវ ឬតម្រូវការពីអ្នកធ្វើ

ការសំរេចចិត្តដែលពាក់ព័ន្ធនោះប្រហែលជាវិធីសាស្ត្រនៃការអភិវឌ្ឍន៍សហគមន៍ធម្មតា របស់យើងគ្រប់គ្រាន់ហើយ ។ ម្យ៉ាងវិញទៀតប្រសិនបើ ការផ្លាស់ប្តូរគោលបំណង ចាំបាច់ដោយមានឥទ្ធិពលទៅលើអ្នកណាម្នាក់ដែលអាចសំរេចចិត្តទៅលើ លទ្ធផលនោះការតស៊ូមតិវិធីសាស្ត្រដ៏ត្រឹមត្រូវ ។

| ឧទាហរណ៍ផ្សេងៗនៃការអភិវឌ្ឍន៍សហគមន៍ធម្មតា | | |
|---|---|---|
| ធ្វើការដើម្បីផ្លាស់ប្តូរ | អ្នកទទួលផល | លក្ខណៈនៃអ្នកទទួលផល |
| 1. *ចំណោទ/បញ្ហា* ភូមិខ្វះខាតទឹក ជាពិសេសនៅរដូវប្រាំង ។ <br> -*គោលបំណង* : ជីកអណ្តូងដែលធ្វើឱ្យមានសារៈប្រយោជន៍ដល់សហគមន៍ទាំងមូល ។ | អ្នកភូមិ | អ្នកភូមិក្រីក្រ និងខ្វះខាតធនធាន |
| 2. *ចំណោទ/បញ្ហា* ស្ត្រីរស់នៅក្នុងសហគមន៍ ជាពិសេសស្ត្រីមេម៉ាយ និងអ្នកលែងលះគ្នាមិនអាចរកប្រភពផ្សេងៗ សំរាប់ជីវភាពរស់នៅ ពីព្រោះពួកគេខ្វះខាតចំណេះដឹង និងជំនាញ ។ <br> -*គោលបំណង* : ផ្តល់ដល់ស្ត្រីនូវចំណេះដឹងខាងសរសេរគិតគូរលេខដែលអាចធ្វើការងារបាន និងជំនាញក្នុងការរកប្រាក់ចំណូល ។ | ស្ត្រីក្រីក្រមិនចេះអក្សរ និងគ្មានការងារធ្វើនៅក្នុងសហគមន៍ ។ | ស្ត្រីជាអ្នកដែលនៅក្នុងចំណោមអ្នកទន់ខ្សោយជាងគេនៅក្នុងសហគមន៍ ពីព្រោះពួកគេក្រីក្រ និងគ្មានអំណាច ។ |
| 3. *ចំណោទ/បញ្ហា* អ្នកភូមិកំពុងទទួលរងគ្រោះអំពីបញ្ហាសុខភាពផ្សេងៗ។ <br> *គោលបំណង :* ដើម្បីដោះស្រាយបញ្ហាសុខភាពនៅក្នុងសហគមន៍ដោយបញ្ជូនក្រុមគ្រូពេទ្យជំនួយចល័ត ឬផ្តល់វគ្គបណ្តុះបណ្តាលទៅលើសុខភាព និងការប្រើប្រាស់ទឹកស្អាត ។ | អ្នកភូមិដែលមានជំងឺ | អ្នកភូមិទាំងនេះមិនអាច មានលទ្ធភាពទិញថ្នាំនៅពេលដែលគេមានជំងឺ ។ |
| 4. *ចំណោទ/បញ្ហា* <br> កសិករមានផលិតភាពកសិកម្មទាប ។ | កសិករក្រីក្រ | កសិករក្រីក្រទាំងនេះមិនមានប្រភពធនធាន(ដូចជា ចំណេះវិជ្ជា |

| | | |
|---|---|---|
| *គោលបំណង* :ដើម្បីបង្កើនទិន្នផលកសិកម្ម ដល់កសិករតាមរយៈការផ្តល់នូវវគ្គបណ្តុះបណ្តាល ផ្តល់នូវសំភារៈដូចជាជីគីមី ថ្នាំសំលាប់សត្វល្អិត និងហេដ្ឋារចនាសម្ព័ន្ធ ។ | | ឬជំនាញ) ដើម្បីបង្កើនទិន្នផលកសិកម្ម ។ |




| ឧទាហរណ៍ផ្សេងៗនៃការតស៊ូមតិ | | |
|---|---|---|
| ធ្វើការដើម្បីផ្លាស់ប្តូរ | មុខសញ្ញាតស៊ូមតិ | លក្ខណៈនៃមុខសញ្ញាតស៊ូមតិ |
| *1. ចំណោទ/បញ្ហា* ភូមិខ្វះខាតទឹកដោយសារប្រធានភូមិអះអាងថា អណ្តូងដែលបានផ្តល់អោយសហគមន៍ដោយអង្គការអន្តរជាតិជារបស់ផ្ទាល់ខ្លួន ។<br><br>*គោលបំណង* : ដើម្បីឱ្យប្រធានភូមិផ្អាកការអះអាងថា | ប្រធានភូមិឬ ប្រធានឃុំ | ប្រធានភូមិមានអំណាចជាងអ្នកភូមិ ។<br><br>ប្រធានឃុំមានអំណាចជាងប្រធានភូមិ ។ |

| | | |
|---|---|---|
| ជាអណ្ដូងផ្ទាល់ខ្លួនទៅជារបស់ឃុំរួមនៅក្នុងសហគមន៍។ | | |
| 2. *ចំណោទ/បញ្ហា* ឧប្បត្តិហេតុនៃ អំពើហិង្សាក្នុងគ្រួសារ(ប្រពន្ធ និងកូនវាយគ្នា)គឺខ្ពស់នៅក្នុងភូមិវាយគ្នា<br><br>*គោលបំណង :* លុបបំបាត់ ឬកាត់បន្ថយនូវអំពើហិង្សាក្នុងគ្រួសារ ។ | ប្ដីដែលវាយប្រពន្ធ និងកូនរបស់គេ ប្រធានភូមិ ឬ អាជ្ញាធរប៉ូលីស | ប្ដីតែងតែមានកំលាំងនិងសេដ្ឋកិច្ចខ្លាំងជាងអ្នករងគ្រោះដែលមាន ។<br><br>ប្រធានភូមិមានសិទ្ធិអំណាច និងឥទ្ធិពលក្នុងការដោះស្រាយជំលោះរៀបចំសណ្ដាប់ធ្នាប់នៅក្នុងសហ-គមន៍ ។<br><br>អាជ្ញាធរប៉ូលីសមានសិទ្ធិអំណាច និងឥទ្ធិពល ក្នុងការអនុវត្តន៏ច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ។ |
| 3. *ចំណោទ/បញ្ហា* អ្នកភូមិកំពុងទទួលរងគ្រោះអំពីបញ្ហាសុខភាពផ្សេងៗ។<br>*គោលបំណង :* ដើម្បីដោះស្រាយបញ្ហាសុខភាពនៅក្នុងសហគមន៍ដោយបង្កើតគ្លីនិច និងសេវាកម្មនៅពេញផ្ទៃប្រទេស ។ | ក្រសួងសុខាភិបា-ល និងសភាជាតិ | ក្រសួងសុខាភិបាលមានសិទ្ធិអំ-ណាចដើម្បីដាក់ស្នើនូវពង្រាងច្បាប់ស្ដីពីការបង្កើតគ្លីនិច និងសេវាកម្មសុខភាពនៅក្នុងពេញប្រទេស ។<br><br>សភាជាតិមានសិទ្ធិនិងអំណាចដើម្បីអនុម័តច្បាប់ទាំងនេះ ។ |
| 4. *ចំណោទ/បញ្ហា* កសិករមានផលិទ្ធភាពកសិកម្មទាប ។<br><br>*គោលបំណង* ដើម្បីបង្កើនទិន្នផលកសិកម្មដល់កសិករតាមរយៈការផ្ដល់នូវវគ្គបណ្ដុះបណ្ដាល ផ្ដល់នូវសំភារៈ | ក្រសួងកសិកម្ម ក្រសួងបរិដ្ឋាន និងសភាជាតិ | ក្រសួងកសិកម្ម ក្រសួងបរិដ្ឋានមានសិទ្ធិអំណាចដាក់ស្នើសុំពង្រាងច្បាប់ ដើម្បីបង្កើនផលិទ្ធភាពកសិកម្ម ។<br>សភាជាតិមានសិទ្ធិ អំណាច ដើម្បី |

| | | |
|---|---|---|
| ដូចជាជីគីមី ថ្នាំសំលាប់សត្វល្អិត និងហេដ្ឋារចនា-សម្ព័ន្ធ ។ | | អនុម័តពង្រាងច្បាប់ស្តីពីការបង្កើនផលិតផលកសិកម្ម ។ |
| *5. ចំណោទ/បញ្ហា* ពង្រាងច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាល គឺកំណត់នូវសេរីភាព និងស្វ័យភាពសម្រាប់អង្គការខ្មែរ ។<br><br>*គោលបំណង:* គ្មានការដាក់លក្ខ័ណ្ឌទៅលើពង្រាងច្បាប់ NGOs ឬក៏ការដាក់លក្ខ័ណ្ឌតឹងតែងទៅលើច្បាប់ផ្សេងៗដែលនិងការពារនូវសេរីភាពការជ្រៀតជ្រែកទៅលើស្វ័យភាពរបស់អង្គការខ្មែរ ។ | សភាជាតិ ឬក្រសួងមហាផ្ទៃ | សភាជាតិមានអំណាចនិងសិទ្ធិ ដើម្បី អនុម័តច្បាប់នានា ។<br><br>ក្រសួងមហាផ្ទៃ មានសិទ្ធិដាក់ស្នើនូវពង្រាងច្បាប់ |




កត់សំគាល់ថានៅក្នុងឧទាហរណ៏ទី ៣ និងទី៤ នៅក្នុងតារាងអភិវឌ្ឍន៏សហគមន៏ជម្មតា និងការតស៊ូមតិ ចំណោទ/បញ្ហាគឺដូចគ្នា តែនៅក្នុងកំរិតសកម្មភាពគឺខុសគ្នា ។ នៅក្នុងឧទាហរណ៏អភិវឌ្ឍន៏សហគមន៏ជម្មតា គោលបំណង និងសកម្មភាពគឺធ្វើនៅតែកំរិតមូលដ្ឋាន ដោយឡែក នៅក្នុងឧទាហរណ៏ការតស៊ូមតិ គឺ សកម្មភាពនៅកំរិតជាតិ ។

ចំណោទ/មូលដ្ឋាន មួយចំនួនអាចដោះស្រាយតាមវិធីសាស្ត្រអភិវឌ្ឍន៍សហគមន៍ផង និងការតស៊ូមតិផង ។ បញ្ហាខ្លះអាចដោះស្រាយដោយសារតែវិធីសាស្ត្រអភិវឌ្ឍន៍សហគមន៍ធម្មតាប៉ុណ្ណោះ ដោយឡែកបញ្ហាមួយចំនួនគឺដោះស្រាយមានប្រសិទ្ធិភាពគឺដោយធ្វើការតស៊ូមតិ ព្រោះវាទាមទារសកម្មភាពនៅកំរិតជាតិ ។

# វិធីសាស្ត្រនៃការតស៊ូមតិ

ផ្ទុយទៅនឹងអ្វីដែលមនុស្សជាច្រើនគិត ការតស៊ូមតិមិនមែនគ្រប់ពេលប្រឆាំងនឹងរដ្ឋាភិបាល ឬអ្នករៀបចំគោលនយោបាយនោះទេ ។ ជាធម្មតាមានវិធីសាស្ត្រតស៊ូមតិជាច្រើនរបៀប ពីការប្រឈមមុខ រហូតដល់របៀបការទូត (មើលគំនូសបំព្រួញខាងក្រោម) ។




មានល្បែងមួយស្តីពីសកម្មភាពនៃការតស៊ូមតិដែលកំណត់ដោយបរិបទ ដែលក្នុងនោះមនុស្សម្នាក់កំពុងប្រត្តិបត្តិការ ។

ក្នុងបរិយាកាសនយោបាយដ៏ចង្អៀតការផ្តួចផ្តើមការតស៊ូមតិប្រព្រឹត្តទៅដោយមិនពេញលេញ ។ ភាពប្រថុយប្រថានគឺ មានទំហំធំ ហើយអាចមានផលលំបាករហូតដល់ស្លាប់ ។ អ្នកធ្វើការតស៊ូមតិ ឬសកម្មជនតស៊ូមតិ អាចទទួលរងនូវការឈឺចាប់ពីការរំខាន និងការគំរាមកំហែងរបួសរាងកាយ និងអាចស្លាប់ ។

ក្នុងបរិយាកាសសង្គមប្រជាធិប្បតេយ្យ អ្នកធ្វើការតស៊ូមតិ មានទីធ្លាទូលាយដែលងាយស្រួលក្នុងការចាប់ផ្តើមសកម្មភាព ។ យ៉ាងណាក៏ដោយការតស៊ូមតិនៅតែមានភាពប្រថុយប្រថានខ្លះៗ តែផលលំបាកមិនរហូតដល់ស្លាប់ទេ ។

# ធាតុសំខាន់ៗនៃការតស៊ូមតិ

អុកស្វាម នៃចក្រភពអង់គ្លេស និងអៀកឡង់ បានធ្វើការតស៊ូមតិជាច្រើនឆ្នាំ ដែលជាផ្នែកមួយនៃអណត្តិរបស់គេ ធ្វើការដើម្បីយុត្តិធម៌សង្គមដោយធ្វើការប្រឆាំងនិងភាពក្រីក្រ ។

ខាងក្រោមនេះជាសេចក្តីដកស្រង់ចេញពីសៀវភៅ ធ្វើការតស៊ូមតិ ! មេរៀនសិក្សាពីអុកស្វាមនៃចក្រភពអង់គ្លេស និងអៀកឡង់ និពន្ធដោយ Dianna Melrose:

## ១. គោលដៅច្បាស់លាស់, គោលបំណង SMART

បញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗរបស់យើងគឺថាយើងព្យាយាមធ្វើការយ៉ាងឿយហត់ និងដោះស្រាយបញ្ហាជាច្រើននៅពេលជាមួយគ្នានោះ ។ នេះគឺជាការធ្វើឱ្យសាយថាមពលរបស់យើង និងយើងមិនសូវមានប្រសិទ្ធិភាពដោយសារតែយើងព្យាយាមធ្វើការច្រើនពេក ។គ្រោះថ្នាក់គឺថាយើងត្បិតត្បៀតលើការវិភាគរបស់យើង ពីព្រោះយើងខ្វះធនធាន ដើម្បីធ្វើការសិក្សាស្រាវជ្រាវអោយបានរឹងមាំទៅក្នុងថា តើផ្នែកដែលតូចវាមានទំនាក់ទំនងទៅនឹង ផ្នែកធំយ៉ាងណាខ្លះ ។

យើងត្រូវកំណត់គោលដៅច្បាស់លាស់ និងគោលបំណង SMART ដែលរួមមានភាពជាក់លាក់ អាចវាស់វែងបាន អាចសំរេចបាន ប្រាកដនិយម និងពេលវេលាច្បាស់លាស់ ។ គោលដៅប្រកបដោយមហិច្ឆតាធំពេកធ្វើឱ្យបាត់ទឹកចិត្ត និងធ្វើអោយបាត់អំណាច ពីព្រោះអ្នកមុខជានឹងមិនដែលទទួលអារម្មណ៏ថាអ្នកទៅដល់កន្លែងណាឡើយ ។

## ២. ការស្រាវជ្រាវ

បន្ទាប់ពីជ្រើសរើស និងបញ្ជាក់បញ្ហាជាក់លាក់ យើងចាំបាច់ត្រូវធ្វើការសិក្សាស្រាវជ្រាវតាមប្រពន្ធ័ត្រឹមត្រូវទៅក្នុងបញ្ហានោះលើគោលនយោបាយដែលមានស្រាប់ និងចេញនូវសំណើកែប្រែគោលនយោបាយ ។ យើងត្រូវតែធ្វើការស្រាវជ្រាវទៅលើដំណើរការនៃការធ្វើការសំរេចចិត្តដែលរដ្ឋាភិបាល ស្ថាប័នហិរញ្ញវត្ថុធអន្តរជាតិ និងភ្នាក់ងារពហុភាគី ប្រត្តិបត្តិការ និងរកអោយឃើញតួសំដែងសំខាន់ៗដែលជាអ្នកអាចធ្វើឱ្យមានភាពខុសគ្នា ។ យើងចាំបាច់ត្រូវដឹងថា ក្រសួងអ្វី ឬនាយកដ្ឋានណា នៅក្នុងរដ្ឋាភិបាលដែលយើង ត្រូវធ្វើការបញ្ចុះបញ្ចូលហើយនណានៅក្នុងក្រសួង ឬនាយកដ្ឋានទាំងនោះដែលយើងគួរតែធ្វើការពិភាក្សាជាមួយ ។ រៀបចំបញ្ជីគោលដៅការធ្វើការតស៊ូមតិទាំងអស់នោះនៅក្នុងស្ថាបន័របស់រដ្ឋាភិបាល និងនៅភ្នាក់ងារពហុភាគី ។

## ៣. សម្ព័នភាព

សម្ព័នភាព និងបណ្តាញ អាចជាចំនុចសំខាន់ណាស់ ដើម្បីធ្វើអោយផលប៉ះពាល់កាន់តែអប្បបរមាសំរាប់អ្នកបញ្ចុះបញ្ចូល ។ ទាំងនោះអាចជាការជ្រើសរើសយកបញ្ហាជាក់លាក់ ឬបង្កើតជុំវិញគោលដៅការតស៊ូមតិកំណត់ណាមួយ ។ ជាឧទាហរណ៏ ធនាគារ អភិវឌ្ឍន៏អាស៊ី ឬជះឥទ្ធិពលដល់ឱកាសដូចជាអាស៊ាន ។ បណ្តាញទាំងនោះធ្វើការបានល្អបំផុតនៅទីណាដែលក្រុមមានលទ្ធភាព ជួបជុំគ្នាដើម្បីធ្វើផែនការរៀបចំធ្វើយុទ្ធសាស្ត្រឱ្យបានមុនក្នុងរយៈពេលវែង ឯកភាពលើទីតាំងការតស៊ូមតិសាមញ្ញៗ និងធ្វើការបែងចែកការងារអោយបានច្បាស់លាស់។

## ៤. ប្រសិទ្ធិភាពនៃយុទ្ធសាស្ត្រ ប្រពន្ធ័ផ្សព្វផ្សាយ

ប្រពន្ធ័ផ្សព្វផ្សាយគឺជាគន្លឹះសំខាន់ដើម្បីទទួលបានជោគជ័យលើការងារតស៊ូមតិ ។ ប្រសិទ្ធិភាពនៃការងារតាមរយៈប្រពន្ធ័ផ្សព្វផ្សាយ គឺមានសារៈសំខាន់ណាស់ពីព្រោះអ្នកនយោបាយ និងអង្គការអន្តរជាតិ និងភ្នាក់ងារពហុភាគីដូចជាអង្គការសហប្រជាជាតិ និងធនាគារពិភពលោកស្តាប់អ្វីដែលប្រពន្ធ័ផ្សព្វផ្សាយនិយាយ ។ តាមរយៈការប្រើប្រាស់ដោយមានការជ្រើសរើសក្នុងចំណោមប្រពន្ធ័ផ្សព្វផ្សាយផ្សេងៗ បញ្ហាដែលមិនមែនជាបញ្ហាដ៏ក្តៅគគុក នៅពេលបច្ចុប្បន្នអាចក្លាយជាបញ្ហាជជែកវែកញែកទាក់ទងនិងនយោបាយ ។

# កត្តាដែលធ្វើអោយការតស៊ូអាចប្រព្រឹត្តទៅបាន

អត្ថន័យនិងការអនុវត្តន៍នៃការតស៊ូមតិខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ និងពីបរិបទនៃរឿងរ៉ាវមួយទៅរឿងរ៉ាវមួយទៀត ។ មានកត្តា២យ៉ាងដែលធ្វើឱ្យការតស៊ូមតិអាចធ្វើទៅបាន ។ វាក៏ជួយបង្កើតសកម្មភាពតស៊ូមតិផងដែរដែលអាចអនុវត្តន៍ក្នុងប្រទេសកំណត់មួយ :

១) ទីធ្លាប្រជាធិប្បតេយ្យ សំដៅចំពោះសៃរៀនក្នុងបរិយាកាសនយោបាយ និងសង្គម ដែលក្នុងនោះមូលដ្ឋាននៃការគោរពសិទ្ធិមនុស្សត្រូវបានអនុវត្តន៍ ។

២) សង្គមស៊ីវិល អាចកំនត់បានគឺជាការប្រមូលផ្តុំអង្គការឯកជនគ្រប់គ្រងដោយខ្លួនឯង ។ មិនចែកចាយផលប្រយោជន៏ដល់អ្នកដែលពាក់ពន្ធ័ និងនាយកតែបំរើគោលបំណងសាធារណៈនៅរដ្ឋ ។

| |
|---|
| កត្តាទាំងពីរនេះពង្រើងគ្នាទៅមុខ ។ ទីធ្លាប្រជាធិបតេយ្យអាចនាំមកនូវការលេចឡើងនូវសង្គមស៊ីវិលដ៏រស់រវើក ។ សង្គមស៊ីវិលម្យ៉ាងទៀតអាចធ្វើអោយទីធ្លាប្រជាធិបតេយ្យកាន់តែទូលាយឡើង ។ ផ្ទុយទៅវិញទោះបីជាយ៉ាងណាក៏ដោយក៏អាចក្លាយជាការពិតដែរ ។ ប្រសិនបើសង្គមស៊ីវិលមិនរឹងមាំទេ ទីធ្លាប្រជាធិប្បតេយ្យអាចនឹងរលាយទៅវិញ ឬមួយទីធ្លាប្រជាធិប្បតេយ្យក្លាយជាគួចចង្អៀតរារាំងមិនអោយសង្គមស៊ីវិលរីកលូតលាស់ឡើង។ |

## វិធីសាស្ត្រដែលបានស្នើឡើង

មុនពេលបង្រៀន សួរសិក្ខាកាមថា ប្រសិនបើមានការតស៊ូមតិត្រូវបានអនុវត្តន៏ក្នុងប្រទេសកម្ពុជានៅពេលមានរបបនយោបាយខុសៗគ្នា ( ឧ. សង្គមរាស្ត្រនិយម សាធារណៈរដ្ឋខ្មែរ កម្ពុជាប្រជាធិបតេយ្យ សាធារណៈរដ្ឋប្រជាមានិតកម្ពុជា អ៊ុនតាក់ ព្រះរាជាណាចក្រកម្ពុជា ) ។ រួចហើយសួរពួកគេថា តើមានវត្តមានសង្គមស៊ីវិលដែរឬទេ ? ឬមួយមានអង្គការក្នុងស្រុកក្នុងពេលនៃរបបគ្រប់គ្រងខុសៗគ្នានេះ ។

## រយៈពេលនៃការតស៊ូមតិ

ក្នុងអង្គការខ្លះ ការតស៊ូមតិ មានបញ្ចូលនៅក្នុងការងាររបស់ពួកគេ ។ ឧទាហរណ៍ អង្គារសេវាកម្មយេស៊ូកម្ពុជា គឺជាសមាជិកនៃយុទ្ធនាការអន្តរជាតិលុបបំបាត់គ្រាប់មីន ។ អង្គការនេះកំពុងចេញមុខជាងគេក្នុងការទប់ស្កាត់គ្រាប់មីននៅកម្ពុជា និងសកម្មផងដែរក្នុងការបញ្ចុះបញ្ចូលនៅថ្នាក់អន្តរជាតិសហការណ៍ជាមួយអងការដែលមានគំនិតដូចគ្នា ។ អង្គការនេះកំពុងធ្វើការតស៊ូមតិ ស្តីពីរបៀបរបបនៃការទ្រទ្រង់តាមរយៈនៃការរៀបចំយុទ្ធនាការផ្សេងៗ ។ សកម្មភាពរបស់អង្គការនេះគឺជារបៀបវារៈក្នុងរយៈពេលវែងក្នុងការទប់ស្កាត់គ្រាប់មីនទាំងស្រុងនៅគ្រប់ប្រទេសទាំងអស់។

ក្នុងអង្គការដទៃទៀត ការតស៊ូមតិធ្វើឡើងដើម្បីឆ្លើយតបចំពោះតែបញ្ហាដែលកើតឡើងប៉ុណ្ណោះ ។ ឧទាហរណ៍ សមាជិកនៃក្រុមការងារស្ត្រី និងក្រុមការងារសង្គមស៊ីវិលបានផ្តួចផ្តើមសរសេរសេចក្តីថ្លែងការណ៍ស្តីពីការរំលោភទៅលើស្ត្រី និងភាពមិនមានទោសចំពោះឧក្រិដ្ឋជនផ្ញើជូននាយករដ្ឋមន្ត្រី (មើលទំព័រទី ២៥)។
ការងារនេះត្រូវបានធ្វើឡើងដើម្បីឆ្លើយតបចំពោះការកើនឡើងឧប្បត្តិហេតុមនុស្សឃាតទៅលើស្ត្រីនិងការខ្វះខាតការពង្រឹងផ្នែកច្បាប់ ដើម្បីធានាសុវត្ថិភាព និងសន្តិសុខសាធារណៈ ។ ការតស៊ូក្នុងករណីនេះត្រូវបានធ្វើឡើងម្តងម្កាល។

# កត្តាសំរាប់យុទ្ធនាការនាំអោយទទួលបានជោគជ័យ

គឺជាការប្រសើរបំផុតសំរាប់អ្នកធ្វើការតស៊ូមតិដែលមានគោលបំណងស្វែងរកការទ្រទ្រង់ដល់យុទ្ធនាការឱ្យមានការរៀបចំផែនការជាមុន-ធ្វើសកម្មភាពផ្អែកលើព្រឹត្តិការណ៍ដែលគិតថានិងកើតមានជាជាងរង់ចាំឱ្យមានព្រឹត្តិ - ការណ៍កើតឡើង ។ ឆក់ឱកាសនៅពេលដែលបញ្ហាកើតឡើងជាជាងគ្រាន់តែមានប្រតិកម្មចំពោះបញ្ហានោះ ។

យុទ្ធនាការដែលទទួលបានជោគជ័យដោយអង្គការ ទោះបីជាយ៉ាងណាក៏ដោយ គឺជាផលិតផលនៃកត្តាបួនសំខាន់ៗ ។ សៀវភៅស្តីអំពីការគ្រប់គ្រងដោយមិនគិតពីការចំណេញ ដោយលោក Mike Hudson រៀបរាប់ពីកត្តាទាំងបួននោះ ។ ខាងក្រោមនេះជាសេចក្តីដកស្រង់ :

## ១- ភាពជាអ្នកដឹកនាំ

យុទ្ធនាការទទួលបានជោគជ័យអាស្រ័យលើបុគ្គលដែលជឿជាក់ក្នុងមូលហេតុ និងអាចផ្តល់យោបល់ចំពោះករណីនេះ ដើម្បីឱ្យមានការផ្លាស់ប្តូរនៅក្នុងអង្គការនិងនៅក្រៅអង្គការដល់សារព័ត៌មាននិងប្រពន្ធ័ផ្សព្វផ្សាយ ។

អង្គការដែលធ្វើយុទ្ធនាការត្រូវការចាំបាច់មនុស្សដែលអាចបង្ហាញហេតុផលនិងអាចហ៊ាននិយាយដោយឯកឯង និងបកស្រាយដោយហេតុផលជាក់ស្តែង ។

## ២- ប្រកបដោយជំនាញឆ្លៃប្រឌិត

ការធ្វើយុទ្ធនាការអាស្រ័យផងដែរ ទៅលើមនុស្សដែលមានជំនាញប្រកបដោយគំនិតឆ្លៃប្រឌិត ដើម្បីដឹកនាំយុទ្ធនាការដែលជិតជាប់នៅក្នុងការស្រមៃរបស់សាធារណជន ។ គឺត្រូវការជំនាញដែលមានចេញផ្សាយក្នុងសេចក្តីប្រកាស និងទំនាក់ទំនងសាធារណៈជាមួយអង្គការផ្សេងៗ ។ អ្នកទាំងនោះត្រូវមានការប៉ុនប្រសប់ក្នុងការគិតទៅក្នុងរូបភាពទាំងនោះ និងបង្កើតផ្លូវថ្មីសំរាប់ទាក់ទងសាធារណៈដោយប្រើសារដែលមានលក្ខណៈសាំញ៉ាំ ។ នៅពេលដែលសារនោះមានភាពច្បាស់លាស់ អង្គការអាចកសាងបានអ្នកគាំទ្រដ៏រឹងមាំដែលអាចផ្តល់ទាំងការគាំទ្រខាងនយោបាយ និងហិរញ្ញវត្ថុ ។

## ៣-ថ្វីគំនិតនយោបាយ

សកម្មភាពនេះ (គឺយុទ្ធនាការ) អាស្រ័យលើផ្នត់គំនិតនយោបាយដើម្បីរៀបចំយុទ្ធនាការដែលអាចធ្វើការប្រយុទ្ធ និងទទួលជ័យជំនះ ។ អង្គការធ្វើយុទ្ធនាការ ត្រូវការអ្នកចាត់ចែង ដែលអាចធ្វើការថ្លឹងថ្លែងអំពីការផ្លាស់ប្តូរដែលអាចសំរេចបាន និងជាអ្នកដែលអាចប្រមូលកំលាំងមនុស្សធ្វើសកម្មភាពឱ្យកើតមានការផ្លាស់ប្តូរ ។ យុទ្ធនាការដែលមិនមានគោលដៅច្បាស់លាស់ នឹងបាត់បង់នូវកំលាំង ។ អង្គការ Greenpeace មានគោលបំណងរយៈពេលខ្លី ហើយហៅខ្លួនគេថា "ឈ្នះតិច" -ជំហានដ៏សំខាន់ក្នុងបញ្ហានយោបាយនាំទៅរកការផ្លាស់ប្តូរនូវអ្វីដែលចង់បានក្នុងរយៈពេលវែង ។

## ៤- ការគ្រប់គ្រង

អង្គការទាំងនោះ ក៏ត្រូវការគ្រប់គ្រងដែរ ។ ការតានតឹងដែលបានដុតរោលឡើងពីមួយថ្ងៃទៅមួយថ្ងៃដោយសារយុទ្ធនាការដែលបានកើតឡើង ប្រជាពលរដ្ឋជាញឹកញាប់តែងចំណាយថាមពលមិនគ្រប់គ្រាន់ក្នុងការគ្រប់គ្រងអង្គការរបស់ពួកគេ ។ ពួកគេ មិនមែនដឹកនាំដោយឧត្តមគតិអង្គការទាំងនោះតែមួយមុខនោះទេ ។ ការទទួលខុសត្រូវតែចែករំលែក ជាមួយនិងបុគ្គលត្រូវតែទទួលខុសត្រូវ ។ ក្រុមត្រូវតែធ្វើការទាំងនៅក្នុង និងកាត់តាមរចនាសម្ព័ន្ធគ្រប់គ្រងខ្សែបណ្តាយ ។ ប្រជាពលរដ្ឋត្រូវតែមានការគ្រប់គ្រង ។ អ្នកគ្រប់គ្រងយុទ្ធនាការត្រូវតែធ្វើការនៅក្នុងគំរោងថវិកា និងមានពត៌មានដែលគេត្រូវការ ដើម្បីប៉ាន់ប្រមាណតំលៃ ។ អ្នករកមូលនិធិចាំបាច់ត្រូវមានលទ្ធភាពក្នុងការប្រៀបធៀប វិធីសាស្ត្រនៃការរកមូលនិធិផ្សេងៗ ។ ក្នុងរយៈពេលខ្លី ការអនុវត្តនៃការគ្រប់គ្រងរួមគ្នាត្រូវការជាចាំបាច់ដើម្បីងាយឱ្យអ្នកទាំងអស់គ្នាធ្វើការសំខាន់ៗទាំងឡាយសំរាប់យុទ្ធនាការ។

# ដំណើរការតស៊ូមតិ និងការបង្កើតយុទ្ធសាស្ត្រ

យុទ្ធនាការទ្រទ្រង់ការតស៊ូមតិគឺជាវដ្ត ឬរង្វង់ដែលរួមមានជាច្រើនតំណាក់កាល ហើយជាញឹកញាប់មានត្រួតស៊ីគ្នា ។ វិទ្យាស្ថានដើម្បីស្រាវជ្រាវអភិវឌ្ឍន៍ កំណត់ដំណើរការដូចខាងក្រោម :

១- ទស្សនៈវិស័យ

២- វិភាគកំរិតថ្នាក់ម៉ាក្រូ និងជ្រើសរើសបញ្ហា និងវិភាគ

៣- និយមន័យបញ្ហា និងរៀបចំគ្រោងបញ្ហា

៤- គំណត់គោលដៅ

៥- ចង្អុលបង្ហាញ និងវិភាគភាគីពាក់ព័ន្ធ និងក្រុមគោលដៅក្នុងការតស៊ូមតិ

៦- បង្កើតយុទ្ធសាស្ត្រ (គាត់ទិច) និងពេលវេលា

៧- អនុវត្តន៍យុទ្ធសាស្ត្រ និងតាក់ទិចទាំងនោះ

៨- វាយតំលៃ និងផលប៉ះពាល់

៩- ការអនុវត្តន៍នៃមេរៀនវាយតំលៃសំរាប់ការខិតខំក្នុងការតស៊ូមតិនៅពេលអនាគត

ដំណាក់កាលទាំង៩ ត្រូវបានបង្ហាញដោយគំនូសបំព្រួញខាងក្រោម :




ដំណើរការតស៊ូមតិ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍

ខាងក្រោមជាការដកស្រង់ ពីសៀវភៅធនធាន ការតស៊ូមតិ រៀបរៀងដោយវិទ្យាស្ថានដើម្បីស្រាវជ្រាវអភិវឌ្ឍន៍ ។ សៀវភៅនេះពិពណ៌នាជំហានខ្លះៗ ក្នុងដំណើរការតស៊ូមតិ ។

### ទស្សនៈវិស័យ

នេះគឺជាដំណើរការបង្កើតគំនិតទស្សនៈអំពីពិភពលោក ។ យុទ្ធនាការតស៊ូមតិដ៏មានប្រសិទ្ធិភាពស្ថិតលើការយល់ដឹងរបស់អង្គការថា តើគេចង់បានសង្គមរបស់គេយ៉ាងម៉េច ។ ទស្សនៈនេះជួយក្រុមក្នុងការជ្រើសរើសបញ្ហាដែលអាចជួយនាំផ្លូវទៅរកការផ្លាស់ប្តូរ និងកំណត់គោលដៅតស៊ូមតិរយៈពេលវែងឆ្ពោះទៅរកការផ្លាស់ប្តូរ។

### វិភាគបរិបទសង្គម

បន្ទាប់ពីការបង្កើតទស្សនៈរយៈពេលវែងនៃគំនិតអំពីសង្គម ក្រុមតស៊ូមតិរកឃើញចំនុចសំខាន់ៗ ដើម្បីកំនត់ខ្លួនគេនៅក្នុងបរិបទសង្គមបច្ចុប្បន្នដែលគេនឹងប្រត្តិបត្តិការ ។ ធ្វើបែបនេះផ្តល់ឱកាសដល់អង្គការក្នុងការវាយតំលៃ ទំនាក់ទំនងកំលាំងនិងថាមពលម៉ាក្រូដែលនឹងជះឥទ្ធិពលដល់ការងារតស៊ូមតិរបស់ពួកគេ ។ មានវិធីជាច្រើនក្នុងការវាយតំលៃប្រភេទនេះ ។

### ការជ្រើសរើស និងវិភាគបញ្ហា

ប្រជាពលរដ្ឋចូលរួមក្នុងការតស៊ូមតិ ពីព្រោះពួកគេជួបប្រទះបញ្ហាដែលគេគិតថាអាចនឹងដោះស្រាយបានឬធ្វើឱ្យប្រសើរឡើងដោយសកម្មភាពឬការសំរេចចិត្តរបស់រដ្ឋាភិបាល ឬដោយស្ថាប័នដែលមានអំណាចផ្សេងទៀតដូចជា សាជីវកម្មចំរុះជាតិសាស្រ្ត និងធនាគារអភិវឌ្ឍន៍ពហុភាគី ។ ដើម្បីបង្កើតយុទ្ធសាស្រ្តការតស៊ូមតិដ៏មានប្រសិទ្ធិភាពគឺជាការសំខាន់ណាស់ត្រូវមានការជ្រើសរើសបញ្ហាក្នុងចំណោមបញ្ហាដ៏ច្រើនមកវិភាគ និងធ្វើការសំរេចចិត្តថា តើមួយណាដែលសមស្របសំរាប់ការតស៊ូមតិ (យោងទៅផ្នែកស្តីពីការជ្រើសរើសបញ្ហានិងការវិភាគជំពូកទី៤ទំព័រ ) ។

### និយមន័យ និងរៀបគ្រោងបញ្ហា

ការកំណត់និយមន័យដ៏ល្អនិងការពិពណ៌នាជួយក្រុមបង្ហាញពីការព្រួយបារម្ភរបស់គេទៅដល់អ្នកស្តាប់ដ៏ច្រើនយ៉ាងមានប្រសិទ្ធិភាព ។ និយមន័យច្បាស់មានសារៈសំខាន់ណាស់សំរាប់រៀបចំយុទ្ធសាស្រ្តការតស៊ូមតិឱ្យបានខ្លាំង និងសមស្រប និងដើម្បីផ្តោតការខិតខំប្រឹងប្រែងរបស់យើង ។ ប្រជាពលរដ្ឋខុសៗគ្នាព្រួយបារម្ភអំពីបញ្ហាដែលជាញឹកញាប់នឹងមានការបកស្រាយខុសគ្នាទៅតាមមូលហេតុ និងដំណោះស្រាយអ្នកខ្លះមិនទទួលស្គាល់នឹងចាត់ទុកថាជាបញ្ហា ។ ដោយសារតែមានការបកស្រាយផ្សេងៗគ្នាអំពីមូលហេតុនៃបញ្ហា និងគំនិតជាច្រើនអំពីដំណោះស្រាយការជជែកវែកញែក និងស្ថានភាពរបស់អ្នកត្រូវពិតឱ្យបានលំអិតចងក្រងជាឯកសារនិងផ្សព្វផ្សាយឱ្យដឹងដល់កន្លែងដែលធ្វើការប្រឆាំង ។ អ្នកត្រូវតែធ្វើបញ្ហានោះឱ្យទៅជា

ការព្រួយបារម្ភដែលមានលទ្ធភាពជាក់នៅក្នុងរបៀបវារៈសាធារណៈ ។

### កំណត់គោលដៅ

នៅពេលរៀបគ្រោងបញ្ហាក្រុមអាចបង្កើតគោលដៅជាច្រើន និងគោលបំណងជាក់លាក់សំរាប់ការតស៊ូមតិរបស់គេ ។ ក្រុមតស៊ូមតិគួរតែអាចបញ្ចូលទស្សនៈរយៈពេលវែងសំរាប់សង្គមមួយដ៏ល្អក្នុងពេលដែលមានគោលនយោបាយដ៏ចង្អៀតដែលគេសង្ឃឹមថា និងសំរេចបានក្នុងរយៈពេលខ្លី ។

### ការវិភាគអំណាចនៃភាគីដែលពាក់ព័ន្ធក្នុងការតស៊ូមតិ

ក្នុងការបង្កើតយុទ្ធសាស្ត្រយើងត្រូវការគំណាក់កាល ដើម្បីចង្អុលបង្ហាញ និងវិភាគអំណាចដែលពាក់ព័ន្ធរបស់បុគ្គលខុសៗគ្នា និងក្រុមផ្សេងៗគ្នាដែលមានការព្រួយបារម្ភអំពីបញ្ហាជាក់លាក់ និងដំណោះស្រាយគោលនយោបាយដែលទាក់ទង ហើយត្រូវបានស្នើឡើងដើម្បីដោះស្រាយបញ្ហានោះ ។ ការវិភាគនេះ ជាមួយនឹងការកំណត់គោលដៅច្បាស់លាស់អាចផ្តល់នូវមូលដ្ឋានសំរាប់រៀបចំយុទ្ធសាស្ត្រ និងរៀបចំជាតាក់ទិចនិងសកម្មភាពផងដែរ ។

### បង្កើតយុទ្ធសាស្ត្រសកម្មភាព និងយុទ្ធសាស្ត្រតាក់ទិច

*តាក់ទិច* ត្រូវបានគេអោយនិយមន័យថា ជាជំហានសំរាប់បង្កើតយុទ្ធសាស្ត្រទូទៅរបស់អ្នក ។ បញ្ហាជាក់លាក់ដែលអ្នក និងក្រុមរបស់អ្នកអាចធ្វើ ដើម្បីគាបសង្កត់ដល់គោលដៅរបស់អ្នក ។ ពេលខ្លះគេតែងចាត់ទុក **តាក់ទិចជាសកម្មភាព** ។

ដើម្បីបង្កើតយុទ្ធសាស្ត្រដ៏សក្តិសិទ្ធមួយយើងត្រូវរៀបចំសកម្មភាពជាក់លាក់ ឬតាក់ទិចដែលមានគោលដៅក្នុងការជះឥទ្ធិពលដល់គោលដៅផ្សេងៗដែលយើងធ្វើការតស៊ូមតិ :

១ អ្នកធ្វើការសំរេចចិត្ត និងអ្នកកាន់អំណាចដែលមានលទ្ធភាពផ្តល់ឱ្យយើងនូវអ្វីដោលយើងចង់បាន ។
២ អ្នកដែលមានអំណាចដើម្បីជះឥទ្ធិពលដល់អ្នកធ្វើការសំរេចចិត្ត ។

ជាផ្នែកនៃដំណើរការរៀបចំ យើងក៏ត្រូវតែធ្វើការវាយតម្លៃតាក់ទិចដែលសមាជិកអង្គការ ឬមណ្ឌលរបស់គេអាចប្រើបានដ៏ប្រសើរបំផុត ដើម្បីបង្កើតអំណាច និងឈានដល់គោលដៅនៃការតស៊ូមតិ ។

ក្នុងករណីដែលគោលដៅប្រឆាំង តាក់ទិចចាំបាច់ត្រូវតែជ្រើសរើសដែលនឹងបន្ថយលទ្ធភាពក្រុមប្រឆាំងដែលការពារមិនចង់អោយក្រុមសំរេចគោលដៅ ។ គឺដោយសារជាផ្នែកនៃការបង្កើតយុទ្ធសាស្ត្រ ក្រុមត្រូវការចង្អុលបង្ហាញនូវតាក់ទិចសមស្រប និងសកម្មភាពដែលត្រូវធ្វើដូចជាការពង្រឹងក្រុម ការប្រមែប្រមូលកំលាំងនិងចងសម្ព័ន្ធភាព ។ ដូចនេះថាមពល និងកំលាំងរបស់គេកើនឡើង និងស្ថិតនៅយូរអង្វែង ។

ជំហានបន្ទាប់ពីទស្សនៈវិស័យ ការវិភាគ និងការធ្វើផែនការ គឺធ្វើការអនុវត្តន៍ផែនការតស៊ូមតិ ។ បន្ទាប់មកទៀត ធ្វើការវាយតំលៃ បន្ទាប់ពីមានការអនុវត្តន៍សកម្មភាពដើម្បីកំណត់អ្វីដែលមិនដំណើរការ និងអ្វីដែលដំណើរការ ។ ការវាយតំលៃអាចធ្វើលើបីផ្នែក :

-ផលប៉ះពាល់លើនយោបាយ.

- សង្គមស៊ីវិល

- ប្រជាធិបតេយ្យ

( យោងទៅលើ សៀវភៅ *ម្ចាស់នៃការជោគជ័យលើគោលនយោបាយ* ជំពូកទី៣ "ទំព័រ ៣៤-៣៥" ) ចេញពីការវាយតំលៃមេរៀន ដោយទាញចេញពីបទពិសោធន៍តស៊ូមតិអាចប្រើប្រាស់សំរាប់បង្កើនការខិតខំសលីការតស៊ូមតិក្នុងពេលអនាគត ។

# សិទ្ធិសេរីភាព និងភាពកិច្ចស្របច្បាប់ របស់សហគមន៍

## I. តើសិទ្ធិសេរីភាព និងភារកិច្ចស្របច្បាប់ គេចង់និយាយពីអ្វី?

**១-សិទ្ធិសេរីភាព :** គឺជាគោលការណ៍នានា ដែលគេបានចែងក្នុងរដ្ឋធម្មនុញ្ញ របស់ប្រទេសយើង ឬអង្គការសហប្រជាជាតិ ដើម្បីទទួលស្គាល់សេចក្តីថ្លៃថ្នូររស់នៅជាប្រចាំរបស់មនុស្ស ហើយមានស្មើៗគ្នា ដែលមិនអាចលក់ ប្តូរ ផ្ទេរ ឬដកហូតបាន ជាគ្រឹះនៃការបង្កើតឱ្យមានសេរីភាព យុត្តិធម៌ និងសន្តិភាព ក្នុងពិភពលោក។

**២-ភារកិច្ចស្របច្បាប់:** គឺជាការករណីយកិច្ច ដែលប្រជាពលរដ្ឋគ្រប់រូបត្រូវតែប្រតិបត្តិឱ្យខាងតែបាន តាមការកំណត់របស់ច្បាប់ទំលាប់។

## II. ប្រធានបទពិភាក្សា និងប្រមូលផ្តុំគំនិត

### ☞ សំណួរពិភាក្សាប្រធានបទទី ០១

**តើប្រជាពលរដ្ឋយើង ត្រូវការសិទ្ធិសេរីភាពមូលដ្ឋានអ្វីខ្លះ សំរាប់ការរស់នៅក្នុងសង្គម ?**

| សិទ្ធិសេរីភាពស្របតាមច្បាប់ | កាតព្វកិច្ចស្របតាមច្បាប់ |
|---|---|
| • សិទ្ធិជ្រើសតាំងស្រុក, សិទ្ធិទទួលការអប់រំ, សិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត<br>• សិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា, សិទ្ធិស្ម័យសំរេច<br>• សិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី, សិទ្ធិជឿជំនឿសាសនា-ទំនៀមទំលាប់<br>• សិទ្ធិរស់រានជីវិត (សិទ្ធិមានអាហារ ជំរកស្នាក់នៅ សន្តិសុខផ្ទាល់ខ្លួន សុខភាព សំលៀកបំពាក់)<br>• សិទ្ធិមានការងារធ្វើ<br>• សិទ្ធិមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទស្រីឬប្រុស ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត<br>• សិទ្ធិមិនប្រកាន់សញ្ជាតិ ឬវណ្ណៈដើម ។<br>• សិទ្ធិតាំងទីលំនៅថ្មី<br>• សិទ្ធិជារបស់កម្មសិទ្ធិ ។ល។<br>• ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរាងកាយបុគ្គលណាមួយឡើយ ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូរ របស់ប្រជាពលរដ្ឋ (រដ្ឋធម្មនុញ្ញ ) | |

## ☞ សំណួរពិភាក្សាប្រធានបទទី០២

| តើសហគមន៍មូលដ្ឋាន មានសិទ្ធិសេរីភាព និងកាតព្វកិច្ចស្របតាមច្បាប់អ្វីខ្លះ ក្នុងកម្មសិទ្ធិដីធ្លី? | |
|---|---|
| **សិទ្ធិសេរីភាពស្របតាមច្បាប់** | **កាតព្វកិច្ចស្របតាមច្បាប់** |
| • មានតែរូបវន្តបុគ្គល ដែលមានសញ្ញាតិជាខ្មែរ អាចជាម្ចាស់លើទ្រព្យសម្បត្តិ(ច្បាប់ដីធ្លី មាត្រា៨,៩)<br>• ប្រជាពលរដ្ឋមានសិទ្ធិកាន់កាប់ដីជាបុគ្គល ឬជាសមូហភាព (រដ្ឋធម្មនុញ្ញ មាត្រា៤៤)<br>• គ្មានបុគ្គលណាមួយ ត្រូវបានគេដកហូតកម្មសិទ្ធិដីរបស់ខ្លួនបានទេ បើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារៈ (ច្បាប់ដីធ្លី មាត្រា៥)<br>• ព្រទ្យសម្បត្តិឯកជនរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈអាចលក់ ការដូរ ការបែងចែក ឬការផ្ទេរសិទ្ធ តាមការកំណត់ដោយច្បាប់ (ច្បាប់ដីធ្លី មាត្រា១៧)<br>• កម្មសិទ្ធិដីករអាចធ្វើនៅលើដី រាល់ការជាំដុះ ការរៀបចំនិងសាងសង់ តាមបំណងរបស់ខ្លួន លើកលែងតែច្បាប់ហាមឃាត់ (ច្បាប់ដីធ្លី មាត្រា៤៧)<br>• អ្នកកាន់កាប់អចលនវត្ថុទាំងឡាយ មិនអាចក្លាយទៅជាស្របច្បាប់ ក្នុងករណីភោគីបំពេញមិនបានលក្ខខ័ណ្ឌច្បាប់ ដោយហេតុមកពីការកេងបន្លំ ឬដោយអវិយាបទលួចលាក់នឹងច្បាប់ ឬដែលមិនចេញមុខ ឬដោយប្រើហឹង្សា (ច្បាប់ដីធ្លី មាត្រា៣៤,៣២) | • កោះតូច កោះធំ និងដីដុះទាំងឡាយដែលនឹងកកើតថ្មីក្នុងផ្ទៃទន្លេ ឬស្ទឹង ព្រែក ដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន ជារបស់រដ្ឋ (ច្បាប់ដីធ្លី មាត្រា១០២) ។<br>• គ្មានការចាប់យកដីតាមទំនើងចិត្តណាមួយ លើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ឬនីតិបុគ្គលសាធារណៈ (ច្បាប់ដីធ្លី មាត្រា៥)<br>• ការហាមឃាត់មិនឲ្យ (ច្បាប់ជលផល ២៨, ៣៤)<br>-ការពង្រីកផ្ទៃដីកសិកម្មត្រូវហាមឃាត់<br>-ហាមឃាត់ ការធ្វើទំនប់កាត់បឹង ព្រែក ស្ទឹង ទន្លេ ឬផ្លូវទឹកណាមួយ និងការជីកប្រឡាយ ស្រះ រណ្តៅ ឬការសាងសង់ផ្សេងៗ<br>-ហាមឃាត់ ការផ្តល់កម្មសិទ្ធិដីធ្លី នៅក្នុងនាទីដីលិចទឹក ដែលត្រូវការពារ<br>-ការផ្តល់កម្មសិទ្ធិដីធ្លីនៅក្នុងដែននេសាទ អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការអនុញ្ញាត ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ តាមសំណើររបស់ប្រធានរដ្ឋបាលនេសាទ ។ |

## ☞ សំណួរពិភាក្សាប្រធានបទទី ០៣

| តើសហគមន៍មូលដ្ឋាន មានសិទ្ធិសេរីភាព និង ភារកិច្ចស្របតាមច្បាប់អ្វីខ្លះ ក្នុងការប្រើប្រាស់ធនធានធម្មជាតិ/ធនធាននេសាទ ? | |
|---|---|
| **សិទ្ធិសេរីភាពស្របតាមច្បាប់** | **ភារកិច្ចស្របតាមច្បាប់** |
| • ការធ្វើនេសាទលក្ខណៈគ្រួសារ គឺគ្រាន់តែសំរាប់ផ្គត់ផ្គង់ផលនេសាទ ដល់គ្រួសារប៉ុណ្ណោះ ហើយអាចប្រព្រឹត្តទៅបាន គ្រប់ពេលវេលា នៅក្នុងដែននេសាទដែលត្រូវការពារ ក្នុងកន្លែងនេសាទគ្រួសារ ក្នុងរដូវបិទនេសាទនៅក្នុងឡូត៍នេសាទ នៃដែនទឹកសាប ដោយប្រើឧបករណ៍នេសាទគ្រួសារ (ច្បាប់នេសាទមាត្រាទី១៥) ។<br>• ការធ្វើនេសាទជាលក្ខណៈគ្រួសារ នៅកន្លែងនេសាទគ្រួសារ ដែលស្ថិតនៅរដូវបើកនេសាទ អាចប្រព្រឹត្តទៅបាន លុះត្រាតែគោរពតាម ការកំណត់នៅក្នុងបន្ទុកឡូត៍នេសាទ (ច្បាប់នេសាទមាត្រា៨៣)។<br>• សិទ្ធិប្រមូលអនុផលព្រៃឈើ សំរាប់ការប្រើប្រាស់ជាប្រពៃណី (ច្បាប់ព្រៃឈើមាត្រា៤៣)។<br>• ជនគ្រប់រូបក្រៅពីសមាជិកសហគមន៍នេសាទ មានសិទ្ធិប្រើប្រាស់ធនធានជលផល ក្នុងដែននេសាទសហគមន៍ ត្រូវតែមានការអនុញ្ញាតពីសហគមន៍ និងប្រតិបត្តិតាមលិខិតបទដ្ឋាន គតិយុត្តិនានា ដែលពាក់ព័ន្ធនឹងវិស័យជលផល គោលការណ៍ណែនាំ ផែនការ គ្រប់គ្រង លក្ខន្តិកៈ និងកិច្ចព្រមព្រៀង របស់ សហគមន៍នេសាទ (អនុក្រឹត្យសហគមន៍នេសាទមាត្រា១៤)<br>• ប្រជារាស្ត្រដែលមានទីលំនៅក្នុងឡូត៍នេសាទ (សៀវភៅបន្ទុកឡូត៍អាជីវកម្មនេសាទ ប្រការ១១):<br>– អាចធ្វើដំណើរដឹកជញ្ជូនទំនិញសព្វគ្រប់ប្រភេទ ដែលចិញ្ចឹមឬផលនេសាទដែលចាប់បាន ក្រៅពីនាទីឡូត៍នេសាទ ឆ្លងកាត់ចុះឡើង<br>– អាចប្រើប្រាស់ទឹកសំរាប់សេចក្តីត្រូវការក្នុងគ្រួសារបង្កបង្កើនផលស្រូវនិងដំណាំផ្សេងៗ | • នៅក្នុងរយៈពេលបើកនេសាទ ត្រូវហាមឃាត់ ការធ្វើនេសាទជាលក្ខណៈគ្រួសារ ឬសិប្បកម្ម ក្នុងដែននេសាទដែលត្រូវការពារត្រង់ចំណុចដែលមានចំងាយ២០០ម៉ែត្រពីព្រំប្រទល់ឡូត៍ បឹង ព្រែក ផ្នែកខាងមុខច្រកចេញ-ចូលចរាចរត្រីឬផ្នែកខាងបរិវេណដែលប្រើរងព្រួល (សៀវភៅបន្ទុកឡូត៍អាជីវកម្មនេសាទ ប្រការ១១):<br>• ក្រុមប្រឹក្សាឃុំ ត្រូវធ្វើការសិក្សាវាយតំលៃពីការប្រើប្រាស់ការធនធន និងតម្រូវការរបស់ប្រជាជនតាមមូលដ្ឋាន ក្នុងការរៀបចំផែនការ អភិវឌ្ឍន៍ (ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់)<br>• ការកាប់ព្រៃលិចទឹកត្រូវហាមឃាត់<br>• ការហាមឃាត់មិនឲ្យ ធ្វើក្នុងដែននេសាទ (ច្បាប់ជលផលមាត្រា២៨, ៣១ ,៣៣, ៣៨, ៦៤ )<br>-ការចាប់ ការលក់ ការទិញ ការធ្វើសន្និធិ និងការដឹកជញ្ជូនកូនត្រី ឬពងត្រី និងកូន ឬពងវារីសត្វផ្សេងទៀត<br>-ការធ្វើទំនប់កាត់បឹង ព្រែក ស្ទឹង ទន្លេ ឬផ្លូវទឹកណាមួយ និងការជីកប្រឡាយ ស្រះ រណ្ដៅ ឬការសាងសង់ ផ្សេងៗ<br>-ការដាំ ឬការថែរក្សាដំណាំឈូក ក្នុងដែននេសាទ<br>-ពង្រីកផ្ទៃដីកសិកម្ម ការកាប់ព្រៃលិចទឹក<br>-ការចាប់ ដាក់អន្ទាក់ ការធ្វើឲ្យរបួស ការសំលាប់ ការដឹកជញ្ជូន ការលក់ ការទិញ ការកែច្នៃ |

| សិទ្ធិសេរីភាពស្របតាមច្បាប់ | កាតព្វកិច្ចស្របតាមច្បាប់ |
| --- | --- |
| | និងការធ្វើសន្និធិ សត្វស្លាប ទឹកគ្រប់ប្រភេទ ។<br>-ការផ្តល់កម្មសិទ្ធិដីធ្លី នៅក្នុងនាទីដីលិចទឹកដែលត្រូវការពារ<br>-ការធ្វើនេសាទជាលក្ខណៈសិប្បកម្ម និងឧស្សាហកម្ម ក្នុងរដូវបិទ<br>-ការធ្វើនេសាទជាលក្ខណៈឧស្សាហកម្ម នៅក្នុងដែននេសាទដែល ត្រូវការពារ<br>-ហាមឃាត់គ្រប់ពេលវេលា និងគ្រប់ទីកន្លែង នូវការធ្វើនេសាទ ក្នុងដែននេសាទដែលត្រូវការ ដោយប្រើឧបករណ៍ គ្រប់ប្រភេទ រួមផ្សំដោយរបាំងព្រួលដែលមានបណ្តោយលើសពី ៥០ម ឬលាតសន្ធឹងលើសពី ២ភាគ៣ នៃទទឹង មុខទឹក ឬធ្វើឱ្យរាំងស្ទះផ្លូវជលយាន្តគ្រប់ប្រភេទ ប៉ុន្តែលប ណ ឬវ៉ាវ ដែលមានប្រវែងតិចជាង ៥០០ម នៅក្នុងបឹងទន្លេសាប អាចអនុញ្ញាតឱ្យធ្វើបាន ពីថ្ងៃទី១ ខែកុម្ភៈ ដល់ថ្ងៃទី២០ ខែឧសភា ក្នុងកន្លែងដែលមាន ចំងាយយ៉ាងច្រើន ៨ គ.ម ពីមាត់ច្រាំង និង១គ.ម ពីព្រំប្រទល់កន្លែងបំរុងទុក ហើយនិងតំបន់ប្រកាស ដោយក្រសួង ។<br>-ការបោះទីតាំងនេសាទ ឬលបណ ឬវ៉ាវនេះ ធ្វើឱ្យរាំងស្ទះផ្លូវ ជលយាន្តគ្រប់ប្រភេទ<br>-ការបោះទីតាំងលបណ ឬវ៉ាវទាំងឡាយ ត្រូវតែចេញឱ្យអស់មុន ថ្ងៃទី៣១ ខែឧសភាពជាចំបាច់<br>-ត្រូវហាមឃាត់ការទិញ ការលក់ ការកែច្នៃ ការធ្វើសន្និធិ និង ការដឹកជញ្ជូនផលនេសាទ ដែលបានមកពីការធ្វើនេសាទខុសច្បាប់ ឬដោយឧបករណ៍ហាមឃាត់ ។ |

## ☞ សំណួរពិភាក្សាប្រធានបទទី ០៤

| តើសហគមន៍មូលដ្ឋាន មានសិទ្ធិសេរីភាព និង កាតព្វកិច្ចស្របតាមច្បាប់អ្វីខ្លះ ក្នុងការអភិរក្សធនធានធម្មជាតិ/ធនធាននេសាទ ? | |
|---|---|
| សិទ្ធិសេរីស្របតាមច្បាប់ | កាតព្វកិច្ចស្របតាមច្បាប់ |
| • ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិសុំបង្កើតសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួន ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត ដើម្បីចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍន៍ និង ប្រើធនធាននេសាទប្រកបដោយនិរន្តភាព (ច្បាប់នេសាទមាត្រា៧៦)។<br>• សហគមន៍មានសិទ្ធិចូលរួមគ្រប់គ្រងធនធានជលផល ស្របតាម លិខិតបទដ្ឋានគតិយុត្តិនានា ដែលពាក់ព័ន្ធនឹងវិស័យជលផល គោលការណ៍ណែនាំ ផែនការគ្រប់គ្រង លក្ខន្តិកៈ និងកិច្ចព្រមព្រៀង របស់សហគមន៍នេសាទ (អនុក្រឹត្យសហគមន៍នេសាទមាត្រា១២)<br>• សហគមន៍មានសិទ្ធិចូលរួមពង្រឹងវិធានការណ៍បង្ការ និងទប់ស្កាត់បទល្មើសជលផល នៅក្នុងដែននេសាទសហគមន៍សាម៉ី ហើយអាចប្តឹងតវ៉ា ផ្តល់ពត៌មាននានា អំពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ សហគមន៍នេសាទ ទៅសមត្ថកិច្ចជលផល រដ្ឋបាលឃុំ សង្កាត់អាជ្ញាធរដែនដី សមត្ថកិច្ចពាក់ព័ន្ធ ដោយផ្ទាល់ តាមរយៈគណៈកម្មការសហគមន៍នេសាទសាម៉ី (អនុក្រឹត្យសហគមន៍នេសាទមាត្រា១២ ) ។<br>• ប្រជាពលរដ្ឋមានសិទ្ធិទទួលពត៌មានតាមសំណូមពររបស់ខ្លួន និងចូលរួមក្នុងការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ (ច្បាប់ការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ មាត្រា១៦) | • ក្រុមប្រឹក្សាឃុំត្រូវគ្រប់គ្រងធនធានឱ្យមានលក្ខណៈប្រកបដោយនិរន្តភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋាន (ច្បាប់គ្រប់គ្រងឃុំ-សង្កាត់មាត្រា៤១)<br>• ក្រុមប្រឹក្សាឃុំ ត្រូវអភិរក្សធនធានធម្មជាតិ និងបរិស្ថាន ក្នុងការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច (ច្បាប់គ្រប់គ្រងឃុំ-សង្កាត់មាត្រា៤៣)<br>• សហគមន៍នេសាទគ្មានសិទ្ធិលក់ ប្តូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ឬធ្វើការជួរ តំបន់គ្រប់គ្រងដោយសហគមន៍ ទៅឱ្យជនណាមួយបានឡើយ (ច្បាប់ជលផលមាត្រា៧៧)។ |

## ☞ សំណួរពិភាក្សាប្រធានបទទី ០៥

| តើសហគមន៍មូលដ្ឋាន មានសិទ្ធិសេរីភាព និងភារកិច្ចស្របច្បាប់អ្វីខ្លះ ក្នុងវិស័យនយោបាយ-សង្គមកិច្ច? | |
|---|---|
| **សិទ្ធិសេរីភាពស្របតាមច្បាប់** | **ភារកិច្ចស្របតាមច្បាប់** |
| • ប្រជាជនតាមមូលដ្ឋានមានសិទ្ធិបោះឆ្នោតជ្រើសរើសមេឃុំ (ច្បាប់គ្រប់គ្រងឃុំ-សង្កាត់មាត្រា៩.១០) និងសិទ្ធិឈរឈ្មោះក្នុងការបោះឆ្នោតគ្រប់អាយុ ១៨ឆ្នាំ (ច្បាប់រដ្ឋធម្មនុញ្ញ មាត្រា៣៤)<br>• ក្រុមប្រឹក្សាឃុំមានអំណាចអនុម័តបទបញ្ញត្តិ (ច្បាប់គ្រប់គ្រងឃុំ-សង្កាត់មាត្រា៤៨.៤៩)<br>• ប្រជាជនមានសិទ្ធិទទួលសំណងត្រឹមត្រូវ ប្រសិនបើរដ្ឋាភិបាលកម្ពុជា ដកហូតយកទ្រព្យសម្បត្តិរបស់ពួកគេ ដើម្បីជាផលប្រយោជន៍ជាសាធារណៈ (ច្បាប់ដីធ្លីមាត្រា៥)<br>• ប្រជាជនមានសិទ្ធិប្ដឹងទៅគណៈកម្មការសុរិយោដី ពីទំនាស់ដីធ្លី បន្ទាប់មកធ្វើបណ្ដឹងឧទ្ធរណ៍ទៅតុលាការ ប្រសិនបើចាំបាច់(ច្បាប់ដីធ្លីមាត្រា ៤៧)<br>• ប្រជាពលរដ្ឋមានសិទ្ធិចូលរួមសំរេច និងតវ៉ាលើការសម្រេចដីធ្លី (មានវិវាទ) ដែលធ្វើឡើងដោយរដ្ឋបាលសុរិយោដី (ច្បាប់ដីធ្លីមាត្រា ២៣៦.២៣៧)<br>• ប្រជាជនមានសិទ្ធិប្ដឹងបរិហារ ប្ដឹងតវ៉ា ប្ដឹងទារសំណងជួសជុលការខូចខាត ដែលបណ្ដាលមកពីអំពើល្មើសច្បាប់ ខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកអង្គការទាំងនោះ (រដ្ឋធម្មនុញ្ញ មាត្រា៣៩)<br>• សហគមន៍មានសិទ្ធិបង្កើតសមាគមន៍ និងអាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមកការពារសមិទ្ធិជាតិ និងសណ្ដាប់ធ្នាប់សង្គម(រដ្ឋធម្មនុញ្ញ មាត្រា៤២)<br>• មានសិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្ម ដោយសន្តិវិធី (អហិង្សា) ទៅតាមក្របខ័ណ្ឌនៃច្បាប់ (រដ្ឋធម្មនុញ្ញ មាត្រា៣៧) | • ប្រជាជនតាមមូលដ្ឋានអាចតម្រូវឱ្យបង់ពន្ធដីទៅតាមក្រុមប្រឹក្សាឃុំ (ច្បាប់គ្រប់គ្រងឃុំ-សង្កាត់មាត្រា៧៥)<br>• ប្រជាពលរដ្ឋគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងច្បាប់នៃប្រទេសកម្ពុជា (រដ្ឋធម្មនុញ្ញ មាត្រា៤៩)<br>• ក្រសួងកសិកម្មមានសិទ្ធិប្រកាសរំសាយសហគមន៍នេសាទជាបន្ទាន់ តាមសំណើររបស់នាយកដ្ឋាននេសាទ នៅពេលដែលសហគមន៍នោះ បានប្រព្រឹត្តសកម្មភាពបង្កឱ្យមានអន្តរាយធ្ងន់ធ្ងរដល់ប្រភពធនធានសោទ (ច្បាប់ជលផលមាត្រា៧៤)។ |

ជាទូទៅ នៅក្នុងសហគមន៍របស់យើង មានប្រជាកសិករ អ្នកជំនួញ មន្ត្រីរាជការរដ្ឋាភិបាល និងប្រជានេសាទ បាននឹងកំពុងប្រព្រឹត្តការងាររកស៊ីរបស់ខ្លួន ឬអជីពរបស់ខ្លួន ។ ជាការពិតនោះ អ្នកទាំងនេះ មានអ្នកខ្លះប្រព្រឹត្តកិច្ចការ ឬការងាររកស៊ីរបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវ និងកាតព្វកិច្ចស្របតាមច្បាប់ រីឯអ្នកខ្លះទៀតមិនប្រព្រឹត្តកិច្ចការ ឬការងាររកស៊ីរបស់ខ្លួន តាមទទួលខុសត្រូវ និង កាតព្វកិច្ចស្របតាមច្បាប់របស់ខ្លួនសោះឡើយ:

សំណួរ:

១. តើសកម្មភាពអ្វីខ្លះ ដែលអ្នកទាំងអស់នោះ បាននឹងកំពុងប្រព្រឹត្ត ដោយ គ្មានការគោរពច្បាប់ (ករណីកិច្ចផ្លូវច្បាប់របស់ខ្លួន)?
(សូមពិនិត្យមើលលើផ្នែកកាតព្វកិច្ចស្របច្បាប់ ក្នុងការកាន់កាប់ដីធ្លី, ប្រើប្រាស់ធនធានធម្មជាតិ, អភិរក្សធនធានធម្មជាតិ, សិទ្ធិនយោបាយ-សង្គមកិច្ច និងសិទ្ធិសេរីភាពក្នុងសង្គម)

២-តាមយោបល់របស់អ្នក សកម្មភាពទាំងនេះ នឹងធ្វើឱ្យប៉ះពាល់អ្វីខ្លះ ដល់ប្រជាពលរដ្ឋសហគមន៍ និងសង្គមជាតិយើង?

៣-តើស្ថាប័នរដ្ឋាភិបាលរដ្ឋាភិបាលណា ឬនរណា អាចធ្វើការកែតំរូវលើបញ្ហាខាងលើនេះ?

ឧឧឧឧឧឧឧឧឧឧ

## សំណួរពិភាក្សា

ធនធានធម្មជាតិរបស់សហគមន៍ បានបំរើសេចក្ដីត្រូវការ និងចិញ្ចឹមមនុស្សលោក គ្រប់ៗគ្នារាប់លានឆ្នាំមកហើយ ។ ប្រជាពលរដ្ឋយើងតែងពឹងផ្អែកលើធនធានទាំងនេះ ដូចជា:

- កាប់ព្រៃឈើ សម្រាប់អុសចំអិនអាហារ សំណង់ផ្ទះសំបែង ថ្នាំព្យាបាល
- នេសាទត្រីនិងចាប់សត្វព្រៃគ្រប់ប្រភេទ សម្រាប់ម្ហូបអាហារ
- បេះបន្លែបង្កាដុះក្នុងព្រៃ និងបន្លែបង្កាដុះក្នុងទឹក សម្រាប់ម្ហូបអាហារ ។ល ។

**សំណួរ:**

១- នៅក្នុងសហគមន៍របស់យើង តើធនធានធម្មជាតិ ឬធនធានជលផលអ្វីខ្លះ ដែលត្រូវទទួលរងការបំផ្លាញ និងបាត់បង់ខូចខាត ? ដោយសារកត្តាអ្វី ?

២- តើសហគមន៍យើង អាចមានបច្ចេកទេសណាមួយទេ ដើម្បីសហការណ៍គ្នា ប្រើប្រាស់ គ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ ឬធនធានជលផល?

៣- តើសហគមន៍អាចធ្វើអ្វីបានខ្លះ ដើម្បីអភិរក្សធនធានធម្មជាតិ?

## សំណួរពិភាក្សា

ដូចយើងទាំងអស់គ្នាបានយល់ហើយថា ឯកសារច្បាប់ផ្សេងៗរបស់ប្រទេសយើង បានការពារ និងធានាសិទ្ធិសេរីភាព និងកាតព្វកិច្ចស្របច្បាប់ សម្រាប់ប្រជាពលរដ្ឋខ្មែរយើង ដើម្បីគ្រប់គ្រងសម្បត្តិធនធានធម្មជាតិរបស់បុគ្គល និងសាធារៈ ដូចជា:

- ប្រជាជនមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើល្មើសច្បាប់ ខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកអង្គការទាំងនោះ (រដ្ឋធម្មនុញ្ញ មាត្រា៣៩)
- ប្រជាពលរដ្ឋមានសិទ្ធិទទួលពត៌មានតាមសំណូមពររបស់ខ្លួន និងចូលរួមក្នុងការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ (ច្បាប់ការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ មាត្រា១៦)

## សំណួរ :

១-តើប្រជាពលរដ្ឋក្នុងមូលដ្ឋានត្រូវធ្វើយ៉ាងណា ប្រសិនបើសិទ្ធសេរីភាពស្របច្បាប់ក្នុងការអភិរក្ស ការប្រើប្រាស់ធនធានធម្មជាតិ ធនធានវលផល ត្រូវគេរំលោភ ?

**តើប្រជាពលរដ្ឋក្នុងមូលដ្ឋានត្រូវធ្វើយ៉ាងណា ប្រសិនបើសិទ្ធសេរីភាពស្របច្បាប់ក្នុងការអភិរក្ស ការប្រើប្រាស់ធនធាន ធម្មជាតិ ធនធានចលផល ត្រូវគេរំលោភ ?**

## ១- វិធីទី០១

គឺត្រូវផ្តល់ពត៌មានជាលាយល័ក្ខអក្សរអំពីអំពើរំលោភ ជូនដល់ស្ថាប័ន អង្គការរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបានការគាំទ្រ ដំណោះស្រាយ:

- អាជ្ញាធរសមត្ថកិច្ច ដែលពាក់ពាក់ព័ន្ធ ដូចជា មន្ត្រីក្រសួងបរិស្ថាន ឬនាយកដ្ឋានជល ផលឬរុក្ខាប្រមាញ់ (មានវិធានការណ៍ដោះស្រាយ)។
- វិធីដែលគួរធ្វើបំផុត គឺការផ្តល់ពត៌មានទៅតុលាការ តាមរយះធ្វើពាក្យបណ្តឹង (មានវិធានការណ៍ដោះស្រាយ)។
- អង្គការមិនមែនរដ្ឋាភិបាល ឬក្លិបមេធាវី (អាចទទួលជំនួយខាងផ្នែកខាងផ្លូវច្បាប់ជាសំខាន់)។
- ទៅគណៈកម្មការសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹងរដ្ឋសភា ព្រឹទ្ធសភា (ជំនួយស៊ើបអង្កេត និងវិធានការដោះស្រាយ ) ។
- ថ្នាក់ដឹកនាំមន្ត្រីរាជរដ្ឋាភិបាលក្នុងខេត្ត ស្រុក ឃុំ ភូមិ (មានវិធានការណ៍ ដោះស្រាយ)។
- ការសែតជាតិ និងអន្តរជាតិ (ជំនួយស៊ើបអង្កេត និងរបាយការណ៍ផ្សព្វផ្សាយ )

## ២- វិធីទី០២

គឺត្រូវផ្តល់ពត៌មានជាលាយល័ក្ខអក្សរអំពីអំពើរំលោភ រួមផ្សំជាមួយញាតិ ដោយមានចុះហត្ថលេខា (ផ្តិតស្នាមមេដៃ) និងបញ្ជូនញាតិ ជូនដល់ស្ថាប័នសមត្ថកិច្ច សាពតិមាន ។

## ៣-វិធីទី០៣

គឺធ្វើបាតុកម្មដោយសន្តិវិធី ឬចាត់តាំងតំណាងសុំជួបជាមួយអាជ្ញាធរ ថ្នាក់ដឹកនាំធំៗរបស់រាជរដ្ឋាភិបាល ដើម្បីទទួលបានដំណោះស្រាយ ។

---

វគ្គបណ្តុះបណ្តាល ស្តីពីសិទ្ធិ និងការទទួលខុសត្រូវស្របច្បាប់ របស់សហគមន៍មូលដ្ឋាន លើធនធានធម្មជាតិ ថ្ងៃទី២១-២៣ ខែឧសភា ឆ្នាំ២០០២-
[illegible]

# សទ្ទានុក្រម

**ទរន្តការ :** ការកត់ត្រាទុកជាប្រចាំក្នុងឯកសារសុរិយោដី នូវរាល់ការប្រែប្រួល ឬការផ្លាស់ប្ដូរដោយយោងតាមឯកសារគតិយុត្ត ។

**ចារី (Perpetrator) :** អ្នកប្រព្រឹត្ត-អ្នកដៃដល់ ។

**ឆន្ទានិសិទ្ធិ (discretion) :** អំណាចដែលប្រគល់ដល់អាជ្ញាធរអោយរើសយកមធ្យោបាយណាមួយតាមចិត្តខ្លួនមកដោះស្រាយបញ្ហាណាមួយ ។

**តតិយជន (Third Porty) :** ជន ឬភាគីទីបីក្នុងរឿង។ អ្នកដទៃ ឬអ្នកក្រៅ។
ឧទាហរណ៍: អ្នកលក់និងអ្នកទិញជាភាគីទីមួយនិងទីពីរ។
អ្នកផ្សេងទៀតក្រៅពីអ្នកលក់និងអ្នកទិញហៅថា តតិយជន។

**នីត្យានុកូល (Legal) :** ដែលកើតមកពីច្បាប់ ដែលច្បាប់កាត់តែងមក ។

**ធម្មានុរូប (Legitimate) :** ដែលមានគុណភាពជាអ្វីមួយតាមច្បាប់ ។
ឧទាហរណ៍: ចៅហ្វាយស្រុក ជាអាជ្ញាធរធម្មានុរូប ។
កូនដែលកើតពីឪពុក-ម្ដាយដែលមានខាន់ស្លាហៅថា កូនធម្មានុរូប ឬកូនខាន់ស្លា ។

**និតិបុគ្គល (Legal Entity) :** ក្រុមមនុស្សដែលច្បាប់ទទួលស្គាល់ថា ជាបុគ្គលដែរតែដទៃពីសមាជិកខ្លួន។
ឧទាហរណ៍: សមាគមន៍ អង្គការ ក្រុមហ៊ុន ... ជានិតិបុគ្គល ។

**ប្រធានសក្តិ (Force Majeure) :** ព្រឹត្តិការណ៍ដែលកើតឡើងមិនអាចដឹងជាមុន មិនអាចប៉ាន់ស្មានជាមុនបាន និងមិនអាចជំនះបាន ។

**ផលុបភោគ (Usufruct) :** សិទ្ធិភោគនិងប្រើប្រាស់ផល និងផលទុនដែលកើតមកពីទ្រព្យជាកម្មសិទ្ធរបស់អ្នកដទៃ ។

| | |
|---|---|
| ផលុបភោគី : | អ្នកបានផលុបភោគ អ្នកស៊ីផល ។ |
| ព្យសនកម្ម (Prejudice) : | ការខូចខាត ឬសេចក្តីវិនាសអន្តរាយដល់រូបកាយក្តី សំភារៈក្តី ដល់ទឹកចិត្តក្តី ដែលបណ្តាលមកពីអំពើរបស់អ្នកដទៃ ។ |
| រូបវន្តបុគ្គល (Natural Person) : | បុគ្គលដែលមានរូបមែនៗ គឺមនុស្សមែនៗផ្ទុយពីនីតិបុគ្គលដែលជាមនុស្សដោយសន្មត់តាមរបៀបច្បាប់ ។ |
| លិខិតយថាភូត : | លិខិតធ្វើតាមរូបមន្តនៃច្បាប់ ដូចជាលិខិតបញ្ជាក់ជាដើម ។ |
| អន្យសិទ្ធិ (Jont Ownership) : | ដែលមានសិទ្ធិពាក់កណ្តាលម្នាក់ ដែលជារបស់ជនពីរនាក់ និងជាព្រំនៃ កម្មសិទ្ធិនៃជនទាំងពីរនាក់នោះផង ។<br>ឧទាហរណ៍: ជញ្ជាំងអន្យសិទ្ធិ គឺជាជញ្ជាំងរបស់ជនពីរនាក់ ដែលមានផ្ទះជាប់ៗគ្នា ។ |
| អវយវភេទ : | ក្នុងច្បាប់អវយវភេទ មានន័យថា ការផ្ទេរសិទ្ធិខ្លះរបស់ខ្លួន លើកម្មសិទ្ធិណាមួយអោយទៅអ្នកដទៃ ។ |
| អវិភាគកម្ម (Indivision) : | ភាពដែលចែកគ្នាមិនបាន។<br>ឧទាហរណ៍: ផ្ទះមួយជាមរតករបស់កូន៥នាក់ ពុះផ្ទះចែកគ្នា ផ្ទះនេះនឹងអន្តរាយជាមិនខាន។ ដូច្នេះ ផ្ទះនេះហៅថា មរតកអវិភាគ ។ |
| អសារកម្មសិទ្ធិ (Bare Ownership) : | កម្មសិទ្ធិដែលគិតអោយផលដល់ម្ចាស់កម្មសិទ្ធិគេហៅថា ម្ចាស់កម្មសិទ្ធិនោះអោយសិទ្ធិខ្លួនទៅអ្នកដទៃស៊ីផលនៃកម្មសិទ្ធិនេះទាំងអស់ ។ |